ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

## អភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ

## ២០១៩-២០២៣

រៀបចំដោយ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ឆ្នាំ២០១៩

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ធ្លាប់រងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវរងការកាប់សម្លាប់ និងធ្វើទារុណកម្មគ្រប់បែបយ៉ាង បណ្តាលឱ្យកម្ពុជាបាត់បង់ធនធានមនុស្សជាច្រើន។ ក្រោយថ្ងៃរំដោះ០៧ មករា១៩៧៩ ទន្ទឹមនឹងការស្តារនិងអភិវឌ្ឍន៍ប្រទេសពីបាតដៃទទេ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារកម្ពុជា ត្រូវបានការពារ និងលើកតម្កើងដោយចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិ ដូចពាក្យស្លោកថា "កុមារជាទំពាំងស្នងឫស្សី"។

បច្ចុប្បន្នរាជរដ្ឋាភិបាល បានបោះជំហានទៅមុខក្នុងការស្តារសង្គម និងសេដ្ឋកិច្ចឡើងវិញ ដែលតម្រូវឱ្យកសាងធនធានមនុស្ស ជំនាញ និងប្រជាជនដែលមានសុខភាពល្អ។ រាជរដ្ឋាភិបាលបានវិភាជធនធានបន្ថែមទៀតដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលក្នុងនោះបានផ្តោតសំខាន់លើការអភិវឌ្ឍសុខុមាលភាពកុមារផងដែរ។ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ជាមធ្យមក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយ ហើយបានប្រែក្លាយខ្លួនជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោក ព្រមទាំងបានឆ្លងកាត់ពីឋានៈប្រទេសចំណូលទាប មកជាប្រទេសចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ កន្លងទៅ។ អត្រាភាពក្រីក្រនៅកម្ពុជាបានបន្ថយធ្លាក់ចុះជាលំដាប់ពីជាង៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹម១៣,៥% ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ស្មានថាស្ថិតនៅក្នុងរង្វង់១០% នាបច្ចុប្បន្ន។ វិស័យសុខាភិបាល អប់រំ និងសង្គមកិច្ច ក៏សម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីនៅមានសេសសល់បញ្ហាប្រឈមមួយចំនួនដែលរាជរដ្ឋាភិបាលត្រូវបន្តដោះស្រាយក៏ដោយ។ ជាមួយនឹងសមិទ្ធផលដ៏ធំធេងនេះ កម្ពុជាមានមហិច្ឆិតាក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិតាមរយៈការប្រែក្លាយខ្លួន ទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និង ជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

ការដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ជាគន្លឹះចំនួន៣ រួមមានៈទី១)ការដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ទី២)ការផ្តល់សេវាថែទាំសុខភាពដែលមានគុណភាព និងមានតម្លៃសមរម្យ តាមរយៈមូលនិធិសមធម៌សុខាភិបាល និងជំនួយឧបត្ថម្ភជាសាច់ប្រាក់ដល់ស្រ្តីសម្រាលកូន ក៏ដូចជាដល់ស្រ្តីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ នៃគ្រួសារក្រីក្រ និងទី៣)គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់២០១៧-២០៣០ ដើម្បីសម្រេចបានគោលដៅ "គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល"។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩-២០២៣ មានគោលដៅបង្កើនប្រសិទ្ធភាពនៃការអនុវត្តសិទ្ធិកុមារនៅកម្ពុជា និងមានគោលបំណងកំណត់អំពីទស្សនវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុករួមទាំងសកម្មភាពជាយុទ្ធសាស្ត្រដើម្បីឱ្យរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធចូលរួមសហការអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ។

ផែនការយុទ្ធសាស្ត្រនេះមានគោលដៅយុទ្ធសាស្ត្រជាអាទិភាពចំនួន៥ រួមមាន ទី១)ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ទី២)បង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស ទី៣)ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ ទី៤)ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួង-ស្ថាប័ន និងទី៥)បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារនៅតាមរាជធានី-ខេត្ត រួមទាំងលទ្ធផលរំពឹងទុកនិងសកម្មភាពជាយុទ្ធសាស្ត្រផងដែរ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន និងក្រុម

ប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដោយធ្វើការស្នើសុំការគាំទ្រថវិកាជាតិពីរាជរដ្ឋាភិបាល ធ្វើការកៀរគរថវិកា និងបច្ចេកទេសពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បរទេសនិងដៃគូអភិវឌ្ឍន៍ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីសហការធ្វើឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុក និងសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តនេះ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសូមធ្វើការអំពាវនាវដល់អ្នកពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តផែនការយុទ្ធសាស្រ្តនេះប្រកបដោយស្មារតីទទួលខុសត្រូវ។ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ អង្គការ ERIKS Development Partner តាមរយៈសម្ពន្ធអង្គការចាប់ដៃ និងអង្គការពាក់ព័ន្ធផ្សេងទៀតដែលបានជួយឧបត្ថម្ភជាថវិកា និងបច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្រ្តនេះ និងអរគុណដល់ថ្នាក់ដឹកនាំ មន្រ្តីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិក្នុងស្រុក បរទេស និងអ្នកពាក់ព័ន្ធដែលបានផ្តល់ធាតុចូលសម្រាប់ផែនការនេះ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ សមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ដឹកនាំ និងមន្រ្តីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បរទេស និងអ្នកពាក់ព័ន្ធទាំងអស់ចូលរួមសហការអនុវត្តផែនយុទ្ធសាស្រ្តនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**វង_សូត**

# មាតិកា


**អារម្ភកថា** ........ i

**មាតិកា** ........ iii

**១. សេចក្តីផ្តើម** ........ ១

១.១ សាវតា និងបរិបទ ........ ១

១.២ សិទ្ធិជាមូលដ្ឋានរបស់កុមារ ........ ២

១.៣ ទំនាក់ទំនងរវាង ផ.យ.អ.ស.ក នឹងផែនការយុទ្ធសាស្ត្រ និងឯកសារពាក់ព័ន្ធ ........ ៤

១.៤ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ........ ៤

១.៥ ទម្រង់ផែនការយុទ្ធសាស្ត្រ ........ ៤

**២. លទ្ធផលសម្រេចបាន និងបញ្ហាប្រឈម** ........ ៥

២.១ លទ្ធផលសម្រេចបាន ........ ៥

២.២ បញ្ហាប្រឈម ........ ៥

**៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ** ........ ៦

៣.១ ចក្ខុវិស័យ ........ ៦

៣.២ បេសកកម្ម ........ ៦

៣.៣ គោលបំណងគោលនយោបាយ ........ ៦

៣.៤ គោលដៅយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក ........ ៧

គោលដៅយុទ្ធសាស្ត្រទី១៖ពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ ........ ៧

គោលដៅយុទ្ធសាស្ត្រទី២៖បង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ ៩

គោលដៅយុទ្ធសាស្ត្រទី៣៖ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ ........ ១០

គោលដៅយុទ្ធសាស្ត្រទី៤៖ពង្រឹងនិងពង្រីកក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន ........ ១១

គោលដៅយុទ្ធសាស្ត្រទី៥៖បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារខេត្ត ........ ១២

**៤. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ** ........ ១៤

**៥. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា** ........ ១៥

៥.១ ថវិកាជាតិ ........ ១៥

៥.២ ធនធានអង្គការ និងដៃគូអភិវឌ្ឍន៍ ........ ១៥

៥.៣ តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ........ ១៥

**៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ........ ១៦

៦.១ ការត្រួតពិនិត្យតាមដាន ........ ១៦

៦.២ ការវាយតម្លៃ ........ ១៦

**៧. សេចក្តីសន្និដ្ឋាន** ........ ១៧

**ឧបសម្ព័ន្ធ៖** ........ ១៧

# ១. សេចក្តីផ្តើម

## ១.១ សាវតា និងបរិបទ

កម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។[1] កម្ពុជាធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ កម្ពុជាគាំពារប្រឆាំងនឹងការងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។[2] យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារជាពិសេសមាត្រា៤៤ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.)តាមអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥។ បន្ទាប់មកនៅឆ្នាំ១៩៩៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកែសម្រួលតាមអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩។ ហើយនៅចុងឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកែសម្រួលតាមព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ដើម្បីជាយន្តការសម្របសម្រួលនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការអនុវត្តសិទ្ធិរបស់កុមារ។

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ០២ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសម្រាប់ទទួលខុសត្រូវសម្របសម្រួលនិងពិនិត្យតាមដានការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមាររួមមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញសេចក្តីសម្រេចលេខ១២៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី-ខេត្ត ដើម្បីជាយន្តការសម្របសម្រួលនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លើការងារទាក់ទងនឹងសិទ្ធិជាមូលដ្ឋានខាងលើ និងសេចក្តីសម្រេចលេខ១២៧ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន ក្នុងការសម្របសម្រួលនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារផងដែរ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំផែនការសកម្មភាពការងារជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៩៥មក។ នៅឆ្នាំ២០១១ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំផែនការយុទ្ធសាស្ត្រ២០១១-២០១៣ ដែលផ្តោតទៅលើគោលដៅយុទ្ធសាស្ត្រ៤ មានដូចជា៖ ទី១.ការសម្របសម្រួល សមត្ថភាព និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.ទី២.ការលើកកម្ពស់ការយល់ដឹងនិងការតស៊ូមតិដើម្បីសិទ្ធិកុមារ ទី៣.ការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ និងទី៤.ច្បាប់និងគោលនយោបាយសម្រាប់កុមារ។ បន្ទាប់មកផែនការយុទ្ធសាស្ត្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ២០១៤-២០១៨ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កុមារជាពិសេសកិច្ចគាំពារពីការរំលោភបំពានផ្សេងៗ ដែលផ្តោតទៅលើគោលដៅយុទ្ធសាស្ត្រ៤ មានដូចជា៖ ទី១.ពង្រឹងប្រព័ន្ធពិនិត្យតាមដាននិងរបាយការណ៍ស្តីពីសិទ្ធិកុមារ ទី២.ពង្រឹងប្រព័ន្ធការការពារកុមារ ទី៣.លើកកម្ពស់ការយល់សិទ្ធិកុមារ និងទាក់ទាញមតិគាំទ្រ និងទី៤ រចនាសម្ព័ន្ធ ក.ជ.ក. កាន់តែរឹងមាំ និងការកៀរគរធនធាន។

---

[1] មាត្រា ៣១ នៃធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[2] មាត្រា ៤៨ នៃធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ដោយឡែកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏បានដាក់ចេញនូវផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍កុមារ ២០១៦-២០១៨ ក្នុងគោលដៅលើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលជំនាញ សុខុមាលភាពសង្គមសម្រាប់កុមារ ពង្រឹងកិច្ចការពារនិងបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ និងការប្រកបដោយគ្រោះថ្នាក់ ពង្រឹងកិច្ចសហការ ការអនុវត្តច្បាប់ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយ ពង្រឹងយន្តការជាតិ សមត្ថភាពបំពេញមុខងារ និងដំណើរការល្អ។

ដើម្បីឆ្លើយតបនឹងបេសកកម្មដែលរាជរដ្ឋាភិបាលប្រគល់ជូនក្នុងនាមជាយន្តការសម្របសម្រួលលើការងារអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ (ផ.យ.អ.ស.ក)២០១៩-២០២៣ ដើម្បីពង្រឹងការសម្របសម្រួលនិងពិនិត្យតាមដានការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមាររួមមានៈ សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម ដោយផ្តោតលើគោលដៅជាយុទ្ធសាស្ត្រចំនួន៥ គឺៈ១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស ៣.ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ ៤.ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួងស្ថាប័ន និង៥.បង្កើនការអប់រំផ្សព្វផ្សាយកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្ត។

## ១.២ សិទ្ធិជាមូលដ្ឋានរបស់កុមារ

សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារដែលប្រកាសឡើងដោយសេចក្តីសម្រេចចិត្តលេខ១៣៨៦(XIV)របស់មហាសន្និបាតអង្គការសហប្រជាជាតិចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ហើយដែលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាសន្ធិសញ្ញាអន្តរជាតិដែលមានចែងពីបទដ្ឋានអប្បបរមាជាសកលនិងពីគោលការណ៍សីលធម៌សម្រាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម។ អនុសញ្ញានេះគឺជាសេចក្តីថ្លែងការណ៍លម្អិតមួយពីសិទ្ធិទាំងឡាយដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយសង្គម សេដ្ឋកិច្ចនិងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ។ នៅមាត្រា៤៨ នៃធម្មនុញ្ញ កម្ពុជាធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ កម្ពុជាគាំពារប្រឆាំងនឹងកាងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

នៅក្នុងអតីតកាលកុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តលើប៉ុណ្ណោះ។ ប៉ុន្តែក្រោយមកអនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់កុមារថា ជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់គឺជាសិទ្ធិដែលគេទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានាដូចជាឪពុកម្តាយ និងរដ្ឋជាពិសេសមន្ត្រីមានសមត្ថកិច្ចដែលមានភារកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ក៏ដូចសិទ្ធិមនុស្សមិនអាចបំបែកពីគ្នាបានទេគឺមានទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។កុមារត្រូវបានចាត់ទុកជាបុគ្គលដែលកើតមកភ្ជាប់ជាមួយសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរស្មើៗគ្នាក្នុងនាមជាមនុស្ស។ មានប្រការខ្លះដែលគួរជៀសវាងដូចជាការប្រកាន់ភេទ ពណ៌សម្បុរ ភាសា ជំនឿសាសនា ដើមកំណើតជាតិ ឋានៈសង្គម ឬស្ថានភាពដទៃ។[3] យោងតាមគោលការណ៍១០យ៉ាងនៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ និងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារមានបណ្តុំសិទ្ធិជាមូលដ្ឋានសំខាន់ៗចំនួន៤គឺៈ

[3]United Nation ***"Declaration and Convention on the Rights of the child"***1993 ; ទំព័រ ១០-១២

រូបភាពទី១៖ សិទ្ធិជាមូលដ្ឋានរបស់កុមារ




**សិទ្ធរស់រានមានជីវិត៖** កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ និងមានសញ្ជាតិ ការបង្ការនិងព្យាបាលសុខភាព សំលៀកបំពាក់ ជំរកស្នាក់នៅសមរម្យ និងមានជីវភាពគ្រប់គ្រាន់ ព្រមទាំងទទួលបានការថ្នាក់ថ្នមអំពីឪពុកម្តាយ អាណាព្យាបាលនិងសង្គម។ កុមារមិនត្រូវទទួលរងការវាយធ្វើបាបឬទារុណកម្មឡើយ។ ឪពុកម្តាយត្រូវយល់ផងដែរថា សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធជាតិនិងសហគមន៍អន្តរជាតិ ក៏មានចំណែកទទួលខុសត្រូវចំពោះសិទ្ធិរស់រានរបស់កុមារផងដែរ មានន័យថាជីវិតកូនរបស់អ្នកស្ថិតនៅក្រោមកិច្ចការពាររបស់សហគមន៍មូលដ្ឋាន អាជ្ញាធរមានសមត្ថកិច្ច និងសហគមន៍អន្តរជាតិ។ ឪពុកម្តាយ ឬអាណាព្យាបាល អាចរងការប្តឹងពីសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធចំពោះអំពើដែលឪពុកម្តាយបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។ ឪពុកម្តាយអាចប្តឹងតវ៉ាប្រឆាំងនឹងអាជ្ញាធរមានសមត្ថកិច្ចអំពីការមិនយកចិត្តទុកដាក់ ឬមិនផ្តល់កិច្ចការពារ ឬបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។

**សិទ្ធិទទួលបាននូវការការពារ៖** ឪពុកម្តាយត្រូវមើលថែរក្សានិងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានាដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេពកាមគុណលើកុមារ ការធ្វើអាជីកម្មលើកុមារ ការលក់ដូរកុមារនិងអំពើដទៃៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍ធំបំផុតរបស់កុមារ។ ឪពុកម្តាយត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារឯទៀតៗ ពីការរំលោភទាំងឡាយដែលអាចកើតមានពីអាជ្ញាធរមូលដ្ឋានឬអាជ្ញាធរជាតិ។ គេអាចបង្កើតសមាគមមាតាបិតានៅក្នុងសហគមន៍មូលដ្ឋានក្នុងគោលបំណងការពារសិទ្ធិកុមារ។ អាជ្ញាធរមូលដ្ឋានក៏មានភារកិច្ចការពារកុមារពីការរំលោភនានាដែលអាចប្រព្រឹត្តដោយឪពុកម្តាយ ឬណាព្យាបាលរបស់កុមារ និងអ្នកមានអំណាចលើកុមារផ្សេងៗទៀតផងដែរ។

**សិទ្ធិអភិវឌ្ឍន៍៖**កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទគឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាព។

**សិទ្ធិក្នុងការចូលរួម៖** កុមារមានសិទ្ធិចូលរួមបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសមាគម និងការប្រជុំនានា និងចូលរួមទទួល និងផ្សព្វផ្សាយព័ត៌មាន អានសៀវភៅ កាសែត ទស្សនាវដ្តី ស្តាប់វិទ្យុ មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណរិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។

## ១.៣ ទំនាក់ទំនងជាមួយនឹងផែនការយុទ្ធសាស្ត្រ និងឯកសារពាក់ព័ន្ធ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ២០១៩-២០២៣ មានសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៥-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ២០១៧-២០២១ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

ផែនការយុទ្ធសាស្ត្រនេះជាផែនទីតម្រង់ផ្លូវឱ្យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីធ្វើឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារឆ្នាំ២០១៩-២០២៣។

## ១.៤ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារឆ្នាំ២០១៩-២០២៣ បានចាប់ផ្តើមដំណើរការរៀបចំនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ដោយអគ្គលេខាធិការដ្ឋាន ក.ជ.ក. បានបង្កើតក្រុមការងារបច្ចេកទេស តាមរយៈសេចក្តីសម្រេចលេខ០៣១ ក.ជ.ក. ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ដើម្បីធ្វើការសម្របសម្រួលជាមួយទីប្រឹក្សាបច្ចេកទេសក្រោមការឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាល អង្គការយូនីសេហ្វ និងសម្ពន្ធអង្គការចាប់ដៃ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ(ផ.យ.អ.ស.ក)តាមរយៈចុះប្រមូលព័ត៌មាន និងជួបប្រជុំជាមួយតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខេត្តរតនគិរី សៀមរាប កណ្តាល និងខេត្តព្រះសីហនុ និងបានរៀបចំកិច្ចប្រជុំពិភាក្សាក្នុងក្រុមការងារបច្ចេកទេសជាច្រើនលើករួមទាំងសិក្ខាសាលាពិគ្រោះយោបល់លើកទី១ជាមួយអ្នកពាក់ព័ន្ធកាលពីខែឧសភា ឆ្នាំ២០១៩ និងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដើម្បីពិនិត្យ និងសម្រេចលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩-២០២៣។

## ១.៥ ទម្រង់ផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ២០១៩-២០២៣ ចែកជា៧ផ្នែក៖ ផ្នែកទី១៖សាវតានិងបរិបទ សិទ្ធិជាមូលដ្ឋានរបស់កុមារ ទំនាក់ទំនងជាមួយផែនការយុទ្ធសាស្ត្រ និងឯកសារពាក់ព័ន្ធ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនិងទម្រង់ផែនការយុទ្ធសាស្ត្រ ផ្នែកទី២៖លទ្ធផលសម្រេចបាន និងបញ្ហាប្រឈម ផ្នែកទី៣៖ទស្សនៈវិស័យ បេសកកម្ម លទ្ធផលរំពឹងទុក និងគោលដៅយុទ្ធសាស្ត្រ ផ្នែកទី៤៖ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ផ្នែកទី៥៖យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រផ្នែកទី៦៖ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងផ្នែកទី៧៖សេចក្តីសន្និដ្ឋាន និងឧបសម្ព័ន្ធ។

## ២. លទ្ធផលសម្រេចបាន និងបញ្ហាប្រឈម

### ២.១ លទ្ធផលសម្រេចបាន

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសម្រេចបាននូវលទ្ធផលមួយចំនួនដែលបានកំណត់ក្នុងគោលដៅយុទ្ធសាស្ត្រៈ ១.ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ ២.ពង្រឹងយន្តការការពារ ៣.លើកកម្ពស់ការយល់ដឹងនិងការទាក់ទាញមតិគាំទ្រ និង៤.បង្កើនសមត្ថភាពស្ថាប័ននិងភាពជាដៃគូនៃផែនការយុទ្ធសាស្ត្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០១៤-២០១៨។[4] រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានចំណុចដៅទាំងឡាយទាក់ទងនឹងភាពក្រីក្រ និងភាពអត់ឃ្លានជាក់ស្តែងអត្រាភាពក្រីក្រត្រូវបានធ្លាក់ចុះមកត្រឹម ១៣,៥% នៅឆ្នាំ២០១៤ និង១០% នៅឆ្នាំ២០១៨ ចំណូលមនុស្សម្នាក់បានកើនពី៥៩០ដុល្លារអាមេរិក នៅឆ្នាំ២០០៧ ដល់រង្វង់ ១.៥៦០ដុល្លារអាមេរិក នៅឆ្នាំ២០១៨។ រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងបានអនុម័តច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ។[5] ទន្ទឹមនឹងនេះអគ្គលេខាធិការដ្ឋានក.ជ.ក បានពង្រឹងសមត្ថភាពផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ផ្នែកការពារកុមារនិងពិនិត្យតាមដាន និងផ្នែកអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស និងបានពង្រឹងពង្រីកក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត ជាពិសេសបានបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស រួមទាំងអ្នកពាក់ព័ន្ធនានាដែលបានចូលរួមអនុវត្តកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារនៅកម្ពុជា។

### ២.២. បញ្ហាប្រឈម

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានអនុវត្តសកម្មភាពមួយចំនួនដែលបានកំណត់ក្នុងគោលដៅយុទ្ធសាស្ត្រទាំង៤ នៃផែនការយុទ្ធសាស្ត្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០១៤-២០១៨ ប៉ុន្តែសកម្មភាព និងចំណុចដៅនៃសូចនាករមួយចំនួនទៀតមិនទាន់បានសម្រេចនៅឡើយដែលតម្រូវឱ្យ ក.ជ.ក ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ (ផ.យ.អ.ស.ក) ២០១៩-២០២៣ ដូចខាងក្រោមៈ

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មិនទាន់មានប្រព័ន្ធការងារពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ប្រមូល និងគ្រប់គ្រងទិន្នន័យសូចនាករទាំងឡាយដែលទាក់ទងនឹងកុមារដែលក្រសួងស្ថាប័នទទួលខុសត្រូវអនុវត្ត។
- ចំណេះដឹងអំពីសិទ្ធិកុមារនៅតាមក្រសួង-ស្ថាប័ន សង្គមស៊ីវិល សហគមន៍ មាតាបិតា នៅមានកម្រិតនៅឡើយ ដែលបង្កការលំបាកក្នុងការចូលរួមទទួលខុសត្រូវបំពេញនូវសិទ្ធិរបស់កុមារ។
- សមត្ថភាពជំនាញរបស់មន្ត្រី និងធនធានទាំងថ្នាក់ជាតិ និងរាជធានីខេត្តនៅមានកម្រិត ដែលធ្វើឱ្យប៉ះពាល់ដល់ការងារសម្របសម្រួល និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ។
- ការបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ននៅមិនទាន់អនុវត្តពេញលេញទៅតាមសេចក្តីសម្រេចលេខ១២៧ ក.ជ.ក. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ធ្វើឱ្យមានការលំបាកក្នុងការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារលើការអនុវត្តសិទ្ធិកុមារ។

---

[4]របាយការណ៍លទ្ធផលសម្រេចបានរយៈពេលប្រាំឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ២០១៤-២០១៨
[5]របាយការណ៍ជាតិលើកទី៤,៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ២០០៨-២០១៨

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី-ខេត្ត នៅមិនទាន់អនុវត្តពេញលេញ ទៅតាមសេចក្តីសម្រេច លេខ១២៦ ក.ជ.ក. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ដោយជួបការលំបាកទាំងធនធាន និងសមត្ថភាព ជំនាញក្នុងការសម្របសម្រួលលើការងារអប់រំផ្សព្វផ្សាយ និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅក្នុងដែន សមត្ថកិច្ចរបស់ខ្លួន។

## ៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ

### ៣.១ ទស្សនៈវិស័យ

កុមារគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសិទ្ធិជាមូលដ្ឋានពេញលេញ។

### ៣.២ បេសកកម្ម

លើកកម្ពស់សិទ្ធិកុមារដោយផ្តោតលើសិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និង សិទ្ធិចូលរួម និងពិនិត្យតាមដានការទប់ស្កាត់ និងឆ្លើយតបចំពោះកេងប្រវ័ញ្ចលើកុមារគ្រប់រូបភាព រួមទាំងអំពើហិង្សា លើកុមារ។

### ៣.៣ គោលបំណងគោលនយោបាយ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩-២០២៣ មានគោលបំណងគោល នយោបាយអនុវត្តមាត្រា៣១ និងមាត្រា ៤៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ព្រម ទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រង់ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" ដោយផ្តោតលើមុំ៖១). ការពង្រឹងគុណភាពវិស័យអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២).ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣).ការលើក កម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤).ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។

**មុំទី១.**ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គឺអភិវឌ្ឍ "ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកទេស ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និង ការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

**មុំទី២.**ការបណ្តុះបណ្តាលជំនាញបច្ចេកទេសគឺសំដៅធានាថា "យុវជនម្នាក់ៗមានជំនាញមួយយ៉ាងតិចប្រចាំ ជីវិត"ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យឈានឡើងមួយកម្រិតទៀត។ ការបណ្តុះបណ្តាលជំនាញ បច្ចេកទេសធ្វើឡើងក្នុងរូបភាពពីរ ដែលមានការផ្សារភ្ជាប់គ្នា គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និងធនធានមនុស្ស នៅក្រៅប្រព័ន្ធអប់រំ ឬក្នុងទីផ្សារការងារ។

**មុំទី៣.**ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ គឺសំដៅលើកកម្ពស់សុខភាពប្រជាជន និងអាហារូបត្ថម្ភដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមប្រកបដោយចីរភាព។

**មុំទី៤.**ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម គឺការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមដើម្បី លើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។

## ៣.៤ គោលដៅយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក

ផែនការយុទ្ធសាស្ត្រនេះមានគោលដៅយុទ្ធសាស្ត្រជាអាទិភាពចំនួន ៥ រួមមានៈ១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស ៣.ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ ៤.ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួងស្ថាប័ន និង៥.បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារថ្នាក់រាជធានី-ខេត្ត រួមទាំងគោលបំណង លទ្ធផលរំពឹងទុក សកម្មភាពជាយុទ្ធសាស្ត្រ និងសូចនាករ។

រូបភាពទី២៖ ទំនាក់ទំនងរវាង ផ.យ.អ.ស.ក ជាមួយនឹងឯកសារពាក់ព័ន្ធ




*គំនូសបំព្រួញ នៃផ.យ.អ.ស.ក ២០១៩-២០២៣*

| | |
|---|---|
| គោលដៅយុទ្ធសាស្ត្រទី១៖ | ពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ |
| **គោលបំណង៖** | ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ដើម្បីធ្វើឱ្យប្រាកដថាកុមារទទួលបានសិទ្ធិជាមូលដ្ឋាននិងឧត្តមប្រយោជន៍។ |
| **លទ្ធផលរំពឹងទុក៖** | ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រមាណ ៧០%មានសមត្ថភាពគ្រប់គ្រាន់ក្នុងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារនៅឆ្នាំ២០២៣ |

**សកម្មភាពយុទ្ធសាស្ត្រ៖**

១.១ សិក្សាស្រាវជ្រាវ ចងក្រង និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែរពាក់ព័ន្ធ

១.២ ពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ

១.៣ ប្រមូលទិន្នន័យ និងវិភាគលើលទ្ធផលការងារពីអ្នកពាក់ព័ន្ធក្នុងការរួមចំណែកអនុវត្តសិទ្ធិជាមូលដ្ឋាននិងទប់ស្កាត់លុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ

១.៤ សហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បរទេស និងដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ក្នុងការរៀបចំប្រមូលទិន្នន័យស្តីពីស្ថានភាពកុមារ

១.៥ ពិនិត្យតាមដាន វាយតម្លៃ និងធ្វើរបាយការណ៍លើការអនុវត្តគោលនយោបាយ កម្មវិធីជាតិ និងបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ

១.៦ សិក្សាស្រាវជ្រាវ និងធ្វើការកំណត់សូចនាករពាក់ព័ន្ធនឹងសិទ្ធិកុមារសម្រាប់ពិនិត្យតាមដានវាយតម្លៃ

តារាងទី២៖ សូចនាករនៃគោលដៅយុទ្ធសាស្ត្រទី១

| ល.រ | សូចនាករ | ចំណុចដៅនៃសូចនាករ | | | | | |
|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
| 1.1 | លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងសិទ្ធិកុមារត្រូវបានរៀបចំនិងបង្កើតឡើង[6] (ចំនួនឯកសារ) | | 2 | 2 | 3 | 3 | 3 |
| 1.2 | ការអនុវត្តសិទ្ធកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានចុះពិនិត្យតាមដាន[7] (ដង) | | 6 | 24 | 24 | 24 | 24 |
| 1.3 | កិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិត្រូវបានរៀបចំឡើង(លើក) | | 2 | 2 | 2 | 2 | 2 |
| 1.4 | កិច្ចប្រជុំផ្លាស់ប្តូរបទពិសោធ និងប្រមូលទិន្នន័យស្តីពីស្ថានភាពកុមារជាមួយអ្នកពាក់ព័ន្ធត្រូវបានរៀបចំឡើង(លើក) | | 1 | 2 | 2 | 2 | 2 |
| 1.5 | ឧបករណ៍ M&E tools សម្រាប់ប្រមូលព័ត៌មាន ឬទិន្នន័យអនុវត្តសិទ្ធិកុមារត្រូវបានបង្កើតឡើង(ឧបករណ៍) | | សិក្សា | បង្កើត (1) | អនុវត្ត | អនុវត្ត | អនុវត្ត |
| 1.6 | មន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់M&E tools សម្រាប់ប្រមូលព័ត៌មាន/ទិន្នន័យ(នាក់) | | 0 | 20 | 50 | 50 | 50 |
| 1.7 | របាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារត្រូវបានចងក្រងឡើង (របាយការណ៍) | | 2 | 2 | 2 | 2 | 2 |
| 1.8 | កិច្ចប្រជុំ/សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក) | | 1 | 1 | 1 | 1 | 1 |
| 1.9 | កិច្ចប្រជុំ/សិក្ខាសាលាពិនិត្យនិងកំណត់សូចនាករពាក់ព័ន្ធសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក) | | 2 | 6 | 6 | 6 | 6 |

[6]១).ច្បាប់ស្តីពីកិច្ចការពារកុមារ ២).គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ៣).ការសិក្សាស្រាវជ្រាវស្តីពីការវិភាគស្ថានភាពដំបូងនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធើណេត និង៤).ឯកសារពាក់ព័ន្ធដទៃទៀត។

[7]មន្ត្រីផ្នែកការការពារ និងពិនិត្យតាមចុះពិនិត្យការអនុវត្តសិទ្ធិនៅតាមក្រសួងស្ថាប័ន និងរាជធានីខេត្ត

| | |
|---|---|
| **គោលដៅយុទ្ធសាស្ត្រទី២៖** | **បង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស** |
| **គោលបំណង៖** | អប់រំផ្សព្វផ្សាយអនុសញ្ញាស្ដីពីសិទ្ធិកុមារ តាមរយៈបទដ្ឋានគតិយុត្តពាក់ព័ន្ធ សៀវភៅរូបភាព ផ្ទាំងរូបភាព វីឌីអូរអប់រំ(ស្ពត) បណ្ណផ្ទត់ បណ្ដាញសង្គម(ប្រព័ន្ធអេឡិចត្រូនិច) សាសនា និងសម្ដែងជាសាច់រឿង និងព្រឹត្តិបត្រព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារដល់កុមារ ប្រជាជន និងអ្នកពាក់ព័ន្ធឱ្យបានយល់ដឹងពីសិទ្ធិកុមារ។ពង្រឹងសមត្ថភាពជំនាញសិទ្ធិកុមារដល់មន្ត្រីបង្គោលថ្នាក់ជាតិ ក្រោមជាតិ និងអ្នកពាក់ព័ន្ធដើម្បីធ្វើការបណ្ដុះបណ្ដាលនិងផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយជាពិសេសដល់តំបន់ដាច់ស្រយាល។ |
| **លទ្ធផលរំពឹងទុក៖** | អត្រា កុមារ ប្រជាជន និងអ្នកពាក់ព័ន្ធទទួលបានចំណេះដឹងអំពីសិទ្ធិកុមារមានការកើនឡើងនៅត្រឹមឆ្នាំ២០២៣ |

## សកម្មភាពយុទ្ធសាស្ត្រ៖

២.១ ផ្សព្វផ្សាយអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារដើម្បីឱ្យមានការយល់ដឹងទូលំទូលាយពីសំណាក់អ្នកពាក់ព័ន្ធ ប្រជាជន និងកុមារផ្ទាល់

២.២ ប្រមូល ចងក្រង ផលិតសៀវភៅរូបភាព ផ្ទាំងរូបភាព វីឌីអូ(ស្ពត) បណ្ណផ្ទត់ និងព្រឹត្តិបត្រព័ត៌មានពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារដើម្បីផ្សព្វផ្សាយដល់កុមារ ប្រជាជននិងអ្នកពាក់ព័ន្ធ

២.៣ ធ្វើសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍដើម្បីទទួលព័ត៌មានដែលពាក់ព័ន្ធនឹងកុមារ និងធ្វើការផ្សព្វផ្សាយ

២.៤ សិក្សាស្រាវជ្រាវពីឯកសារជាតិ អន្តរជាតិ និងចងក្រងមេរៀនស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ និងរៀបចំផែនការបណ្ដុះបណ្ដាលដល់មន្ត្រីបង្គោលពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

២.៥ បណ្ដុះបណ្ដាលស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារដល់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក មន្ត្រីក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន សមាជិក ក.ជ.ក រាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធនានា

២.៦ លើកទឹកចិត្តជនបង្គោលឱ្យមានការចូលរួមសិក្ខាសាលាថ្នាក់អន្តរជាតិស្ដីពីសិទ្ធិកុមារ ដើម្បីផ្លាស់ប្ដូរបទពិសោធន៍

តារាងទី៣៖ សូចនាករនៃគោលដៅយុទ្ធសាស្ត្រទី២

| ល.រ | សូចនាករ | ចំណុចដៅនៃសូចនាករ | | | | | |
|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
| 2.1 | កិច្ចប្រជុំ/វេទិកា/សិក្ខាសាលាផ្សព្វផ្សាយស្ដីពីអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក) | | 2 | 6 | 7 | 10 | 10 |
| 2.2 | សៀវភៅរូបភាពពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង(ក្បាល) | | 1000 | 1500 | 1500 | 2000 | 2500 |
| 2.3 | ផ្ទាំងរូបភាពពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង(សន្លឹក) | | 925 | 1000 | 1125 | 1125 | 1000 |
| 2.4 | វីឌីអូអប់រំ(ស្ពត)ពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង(ស្ពត) | | 1 | 1 | 1 | 1 | 1 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2.5 | បណ្ណផ្ទត់ពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង(សន្លឹក) | | 5000 | 5000 | 5000 | 5000 | 5000 |
| 2.6 | ព្រឹត្តិបត្រព័ត៌មានពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង(ក្បាល) | | 500 | 500 | 500 | 500 | 500 |
| 2.7 | កិច្ចប្រជុំ/សិក្ខាសាលាពិនិត្យឡើងវិញពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ (ប្រជុំ) | | 2 | 3 | 4 | 5 | 5 |
| 2.8 | កិច្ចប្រជុំរៀបចំមេរៀនស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក) | | 1 | 2 | 2 | 1 | 2 |
| 2.9 | មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក ទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ(នាក់) | | 10 | 15 | 20 | 20 | 20 |
| 2.10 | ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័នទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ(នាក់) | | 10 | 20 | 25 | 20 | 30 |
| 2.11 | មន្ត្រីលេខាធិកាដ្ឋាន ក.ជ.ក រាជធានីខេត្តទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ(នាក់) | | 10 | 20 | 25 | 20 | 30 |
| 2.12 | បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ (នាក់) | | 30 | 30 | 40 | 40 | 40 |
| 2.13 | អ្នកដែលបានចូលរួមទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារនៅថ្នាក់ជាតិ(នាក់) | | 3200 | 3200 | 3200 | 3200 | 3200 |

**គោលដៅយុទ្ធសាស្ត្រទី៣៖** **ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ**

**គោលបំណង៖** បង្កើនសមត្ថភាពជំនាញ និងពង្រឹងមនសិការវិជ្ជាជីវៈក្នុងការទទួលខុសត្រូវ របស់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.កនិងមន្ត្រីពាក់ព័ន្ធ ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថានប័ន និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូដើម្បីកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុក៖** មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងមន្ត្រីពាក់ព័ន្ធទទួលបានការពង្រឹងសមត្ថភាពអភិវឌ្ឍជំនាញ និងកៀរគរទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការលើកកម្ពស់សិទ្ធិកុមារប្រកបដោយគុណភាពនៅត្រឹមឆ្នាំ២០២៣។

## សកម្មភាពយុទ្ធសាស្ត្រ៖

៣.១ ពង្រឹងសមត្ថភាពជំនាញមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងអ្នកពាក់ព័ន្ធដើម្បីអនុវត្តមុខងារ

៣.២ រៀបចំផែនការថវិកាកម្មវិធី និងគម្រោងផ្សេងៗទៀត ជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូ

៣.៣ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីកៀរគរការគាំទ្រទាំងថវិកា និងបច្ចេកទេសសម្រាប់លើកកម្ពស់សិទ្ធិកុមារ

៣.៤ ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ

៣.៥ បង្កើត និងពង្រឹងសមត្ថភាពអង្គភាពថវិកាសម្រាប់អគ្គលេខាធិការដ្ឋាន ក.ជ.ក

តារាងទី៤៖ សូចនាករនៃគោលដៅយុទ្ធសាស្ត្រទី៣

| ល.រ | សូចនាករ | ចំណុចដៅនៃសូចនាករ | | | | | |
|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
| 3.1 | មន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលជំនាញរៀបចំផែនការ ពិនិត្យតាមដាន និងជំនាញពាក់ព័ន្ធ(នាក់) | | 10 | 25 | 30 | 40 | 30 |
| 3.2 | មន្ត្រីពាក់ព័ន្ធទទួលបានការអភិវឌ្ឍសមត្ថភាព (នាក់) | | 2 | 4 | 5 | 7 | 8 |
| 3.3 | ផែនការថវិកាកម្មវិធី និងផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានចងក្រងរៀបចំឡើង(ផែនការ) | | 2 | 2 | 2 | 2 | 2 |
| 3.4 | កិច្ចប្រជុំ/សិក្ខាសាលាដើម្បីកៀរគរទាំងថវិកា និងបច្ចេកទេសត្រូវបានរៀបចំឡើង(លើក) | | 2 | 2 | 2 | 2 | 2 |
| 3.5 | កិច្ចប្រជុំ ក.ជ.ក ត្រូវបានរៀបចំឡើង (លើក) | | 2 | 2 | 2 | 2 | 2 |
| 3.6 | ទស្សនៈកិច្ចសិក្សាពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក) | | 1 | 2 | 4 | 5 | 3 |
| 3.7 | អង្គភាពថវិកាសម្រាប់អគ្គលេខាធិការដ្ឋាន ក.ជ.កត្រូវបានបង្កើត និងពង្រឹងសមត្ថភាព(អង្គភាព) | | រៀបចំ | អនុវត្ត (1) | អនុវត្ត | អនុវត្ត | អនុវត្ត |

**គោលដៅយុទ្ធសាស្ត្រទី៤៖** ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន

**គោលបំណង៖** ជំរុញឱ្យក្រសួង-ស្ថាប័នបង្កើតក្រុមការងារដើម្បីកុមារ ធ្វើការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិកុមារដល់មន្ត្រីពាក់ព័ន្ធឱ្យមានចំណេះដឹង ដើម្បីចូលរួមអនុវត្តសិទ្ធិកុមារ និងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារការយកចិត្តទុកដាក់ថែទាំកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន។

**លទ្ធផលរំពឹងទុក៖** កុមារាកុមារីដែលជាកូនមន្ត្រីរាជការ និងកុមារដែលទទួលផលពីកម្មវិធី ឬគម្រោងរបស់ក្រសួង-ស្ថាប័ន ទទួលបាននូវសិទ្ធិជាមូលដ្ឋាននិងបង្កើតឱ្យមានទារកដ្ឋាននៅតាមក្រសួង-ស្ថាប័ននៅត្រឹមឆ្នាំ២០២៣។

**សកម្មភាពយុទ្ធសាស្ត្រ៖**

៤.១ ពង្រឹងសមត្ថភាពក្រុមការងារដើម្បីកុមារ និងលើកគម្រោងថវិកាពីក្រសួង-ស្ថាប័ន ដើម្បីអនុវត្តមុខងារ

៤.២ ពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅក្នុងក្រសួង- ស្ថាប័នដើម្បីធានាបាននូវឧត្តមប្រយោជន៍របស់កុមារ

៤.៣ បណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងកាតព្វកិច្ចរបស់ក្រុមការងារដើម្បីកុមាររបស់ក្រសួង-ស្ថានប័នក្នុងការផ្សព្វផ្សាយ និងអនុវត្តកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ

៤.៤ ផ្សព្វផ្សាយលិខិតទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងកុមារ ព្រមទាំងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងក្រសួង-ស្ថាប័ន

៤.៥ ប្រមូលទិន្នន័យពីស្ថានភាពកុមារ និងបញ្ជ្រាបផែនការ និងកម្មវិធីពាក់ព័ន្ធលើកកម្ពស់សិទ្ធិកុមារទៅក្នុងផែនការ គម្រោងកម្មវិធីរបស់ក្រសួង-ស្ថាប័ន

៤.៦ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមានគម្រោងការងារពាក់ព័ន្ធនឹងសិទ្ធិកុមារនៅក្នុងក្រសួង-ស្ថាប័នដើម្បីកែលម្អស្ថានភាពកុមារ

តារាងទី៥៖ សូចនាករនៃគោលដៅយុទ្ធសាស្ត្រទី៤

| ល.រ | សូចនាករ | ចំណុចដៅនៃសូចនាករ | | | | | |
|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
| 4.1 | ក្រុមការងារដើម្បីកុមារក្រសួងស្ថាប័នត្រូវបានបង្កើតឡើង និងពង្រឹងពង្រីកសមត្ថភាព(ក្រុម)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |
| 4.2 | កិច្ចអន្តរាគមន៍ និងឆ្លើយតបចំពោះអំពើរំលោភសិទ្ធិកុមារត្រូវបានអនុវត្ត(ដង)សម្រាប់១ក្រសួង | | 2 | 6 | 6 | 6 | 6 |
| 4.3 | សមាជិកក្រុមការងារដើម្បីកុមាររបស់ក្រសួងស្ថាប័នត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងតួនាទីក្រុមការងារដើម្បីកុមារ(នាក់)សម្រាប់១ក្រសួង | | 10 | 25 | 25 | 25 | 25 |
| 4.4 | កិច្ចប្រជុំដើម្បីពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |
| 4.5 | កិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |
| 4.6 | កិច្ចប្រជុំបញ្ជ្រាបបញ្ហាកុមារនិងលើកកម្ពស់សិទ្ធិកុមារទៅក្នុងផែនការ កម្មវិធីរបស់ក្រសួង-ស្ថាប័នត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |
| 4.7 | កិច្ចប្រជុំសម្របសម្រួលរវាងអង្គការពាក់ព័ន្ធជាមួយក្រសួងត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |
| 4.8 | ទិវាកុមារអន្តរជាតិ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២ត្រូវបានរៀបចំឡើង(នាក់)សម្រាប់១ក្រសួង | | 1 | 1 | 1 | 1 | 1 |

**គោលដៅយុទ្ធសាស្ត្រទី៥៖** បង្កើនការអប់រំផ្សព្វផ្សាយដើម្បីពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារនៅថ្នាក់រាជធានី-ខេត្ត

**គោលបំណង៖** ផ្សព្វផ្សាយលិខិតទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារដល់កុមារ ប្រជាជន និងអ្នកពាក់ព័ន្ធឱ្យបានយល់ដឹងពីសិទ្ធិកុមារ និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅថ្នាក់រាជធានី-ខេត្ត។

**លទ្ធផលរំពឹងទុក៖** អត្រាកុមារ ប្រជាជន និងអ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី-ខេត្តយល់ដឹងនិងចូលរួមពិនិត្យតាមដាន និងលើកកម្ពស់សិទ្ធិកុមារទូលំទូលាយនៅត្រឹមឆ្នាំ២០២៣

**សកម្មភាពយុទ្ធសាស្ត្រ៖**

៥.១ ពង្រឹងសមត្ថភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត ដើម្បីអនុវត្តមុខងារឱ្យមានប្រសិទ្ធភាព

៥.២ បណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងកាតព្វកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិដល់អ្នកពាក់ព័ន្ធដើម្បីផ្សព្វផ្សាយ និងអនុវត្តកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារនៅថ្នាក់រាជធានី-ខេត្ត

៥.៣ ផ្សព្វផ្សាយលិខិតទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅថ្នាក់រាជធានី-ខេត្ត

៥.៤ បញ្ជ្រាបផែនការ និងកម្មវិធីដែលពាក់ព័ន្ធការលើកម្ពស់សិទ្ធិកុមារទៅក្នុងផែនការថ្នាក់រាជធានី-ខេត្ត និង

ដើម្បីឧត្តមប្រយោជន៍របស់កុមារ

៥.៥ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិនិងដៃគូពាក់ព័ន្ធដែលមានគម្រោង ឬកម្មវិធីនៅថ្នាក់រាជធានី-ខេត្តដើម្បីកែលម្អស្ថានភាពកុមារ

៥.៦ ពង្រឹងនិងពង្រីកការរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា នៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងនៅតាមសាលារៀន

៥.៧ ប្រមូលទិន្នន័យពីស្ថានភាពកុមារ និងពិនិត្យតាមដាន វាយតម្លៃការអនុវត្តសិទ្ធិកុមារដើម្បីមានវិធានការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅថ្នាក់រាជធានី-ខេត្ត។

តារាងទី៦៖ សូចនាករនៃគោលដៅយុទ្ធសាស្ត្រទី៥

| ល.រ | សូចនាករ | ចំណុចដៅនៃសូចនាករ | | | | | |
|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
| 5.1 | ក.ជ.ក រាជធានី-ខេត្ត និងលេខាធិការដ្ឋានត្រូវបានកែសម្រួលឱ្យដំណើរការ និងពង្រឹងសមត្ថភាព(អង្គភាព) | | 2 | 2 | 2 | 2 | 2 |
| 5.2 | កិច្ចអន្តរាគមន៍ និងឆ្លើយតបចំពោះអំពើរំលោភសិទ្ធិកុមារត្រូវបានអនុវត្ត(ដង)សម្រាប់១រាជធានី-ខេត្ត | | 10 | 24 | 24 | 24 | 24 |
| 5.3 | សមាជិក ក.ជ.ក រាជធានីខេត្តត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងតួនាទី ក.ជ.ក(នាក់)សម្រាប់១ខេត្ត | | 13 | 26 | 26 | 26 | 26 |
| 5.4 | មន្ត្រីពាក់ព័ន្ធរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ(នាក់)សម្រាប់១រាជធានី-ខេត្ត | | 20 | 50 | 50 | 50 | 50 |
| 5.5 | ចំនួនកិច្ចប្រជុំពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅក្នុងរាជធានីខេត្តត្រូវបានរៀបចំឡើង(ប្រជុំ)សម្រាប់១រាជធានី-ខេត្ត | | 1 | 2 | 2 | 2 | 2 |
| 5.6 | កិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិដែលពាក់ព័ន្ធនឹងការលើកសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | | 1 | 1 | 1 | 1 | 1 |
| 5.7 | កិច្ចប្រជុំបញ្ជ្រាបបញ្ហាកុមារនិងលើកកម្ពស់សិទ្ធិកុមារទៅក្នុងផែនការ កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | | 1 | 1 | 1 | 1 | 1 |
| 5.8 | កិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃលើការសិទ្ធិកុមារជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | | 1 | 1 | 1 | 1 | 1 |
| 5.9 | ទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ត្រូវបានរៀបចំឡើង(ទិវា) សម្រាប់១រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន | 1 | 1 | 1 | 1 | 1 | 1 |
| 5.10 | របាយការណ៍វឌ្ឍនភាពសូចនាករពាក់ព័ន្ធសិទ្ធិកុមារប្រចាំឆមាស និងប្រចាំឆ្នាំត្រូវបានចងក្រងឡើង(របាយការណ៍) | | 0 | 2 | 2 | 2 | 2 |

## ៤. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

៤.១ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ដែលជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលសម្រាប់ការងារពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ ពិនិត្យតាមដាន វាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញានិងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារនិងដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។[8]

៤.២ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបង្កើតឡើងដោយអនុក្រឹត្យលេខ០២ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ដែលមានរចនាសម្ព័ន្ធដូចជាផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ផ្នែកការពារកុមារនិងពិនិត្យតាមដាននិងផ្នែកអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស ដើម្បីរៀបចំនិងអនុវត្តផែនការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារនានា ពិនិត្យតាមដានស្ថានភាពកុមារ ជំរុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារ សិក្សាស្រាវជ្រាវច្បាប់ជាតិអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ធ្វើសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិន មែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ។

៤.៣ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានចេញសេចក្តីលេខ១២៧ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័នដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លើការងារពិគ្រោះយោបល់ សម្របសម្រួល ពិនិត្យតាមដានវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារគោលនយោបាយ និងលិខិតដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ រៀបចំផែនកម្មវិធី និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់កុមារ និងបញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីរបស់ក្រសួង-ស្ថាប័ននិងធ្វើទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារនៅក្នុងក្រសួង-ស្ថាប័ន ស្វែងរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អ ស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

៤.៤ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្តបង្កើតឡើងតាមរយៈសេចក្តីលេខ១២៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លើការងារសម្របសម្រួល ពិនិត្យតាមដាន វាយតម្លៃ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព។ រៀបចំផែនការ កម្មវិធី និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់កុមារសម្រាប់រាជធានីខេត្ត និងធ្វើទំនាក់ទំនងជាមួយអង្គការ មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារនៅក្នុងរាជធានី-ខេត្តដើម្បីស្វែងរក ជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែសម្អ ស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

---

[8] មាត្រា៨ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០០៩

៤.៥ ភាគីពាក់ព័ន្ធដទៃទៀតដែលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមាររួមមាន ក្រសួង-ស្ថាប័ន កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ វិស័យឯកជន អាជ្ញាធរថ្នាក់ក្រោមជាតិ[9]កុមារនិងឪពុកម្តាយ អាណាព្យាបាលទាំងអស់នឹងផ្តល់ការគាំទ្រ និងសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្តដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានប្រសិទ្ធភាពនិងប្រសិទ្ធផល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

# ៥. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[10](ស.អ.យ)និងមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងប្រភពផ្សេងៗទៀតដើម្បីគាំទ្រសកម្មភាព និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ។

## ៥.១ ថវិកាជាតិ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារក្រសួង-ស្ថាប័ន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្តនឹងខិតខំដាក់បញ្ចូលសកម្មភាពអាទិភាពទៅក្នុងការរៀបចំគម្រោងថវិកាកម្មវិធីប្រចាំឆ្នាំដើម្បីស្នើសុំការវិភាជថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានច្រើនពីមួយឆ្នាំទៅមួយឆ្នាំដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ។

## ៥.២ ធនធានអង្គការ និងដៃគូអភិវឌ្ឍន៍

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានយកចិត្តទុកដាក់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងដៃគូពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើវិស័យកិច្ចការពារសិទ្ធិកុមារដើម្បីស្នើសុំការគាំទ្រ ទាំងថវិកា និងបច្ចេកទេស[11]ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យសម្រេចបានជោគជ័យ។

## ៥.៣ តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារត្រូវការថវិកាប្រមាណ **979,551.00**US$[12]ដើម្បីចំណាយតាមយុទ្ធសាស្ត្រ៖ ១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស ៣.ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ ៤.ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួងស្ថាប័ន និង៥.បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្ត។

---

[9]រដ្ឋបាលថ្នាក់ក្រោមជាតិ៖ក្រុមប្រឹក្សារាជធានីខេត្ត ក្រុងស្រុក ខណ្ឌ គណៈអភិបាលរាជធានីខេត្ត ក្រុងស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់

[10]មាត្រា ១២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០០៩

[11]មាត្រា ១១ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០០៩

[12]តួលេខនេះបូកបញ្ចូលតម្រូវការចំណាយសម្រាប់ ១ក្រសួង-ស្ថាប័នមានក្រុមការងារដើម្បីកុមារ និង ១រាជធានី-ខេត្ត មានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត(តម្រូវការចំណាយនេះអាចកើនឡើងរហូតដល់គ្រប់ក្រសួង-ស្ថាប័ន និង២៥រាជធានី-ខេត្ត)

តារាងទី៣៖ តារាងតម្រូវការថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ

| ល.រ | គោលដៅយុទ្ធសាស្ត្រ | តម្រូវការថវិកា៥ឆ្នាំ |
|---|---|---|
| ១ | ពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ | 306,200.00 US$ |
| ២ | បង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស | 457,000.00 US$ |
| ៣ | ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ | 77,951.00 US$ |
| ៤ | ពង្រឹងនិងពង្រីកក្រុមការងារដើម្បីកុមារក្រសួង-ស្ថាប័ន (១ក្រសួង-ស្ថាប័ន) | 68,500.00 US$ |
| ៥ | បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្ត (១រាជធានី-ខេត្ត) | 69,900.00 US$ |
| សរុបរួម | | 979,551.00 US$ |

## ៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ២០១៩-២០២៣ សម្រេចបានតាមគោលដៅយុទ្ធសាស្ត្រ សកម្មភាពជាយុទ្ធសាស្ត្រ និងចំណុចដៅនៃសូចនាករដែលបានកំណត់។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រគឺជាការងារដ៏សំខាន់តម្រូវឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត នឹងត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយជាមួយអ្នកពាក់ព័ន្ធនានាផ្អែកលើផែនការយុទ្ធសាស្ត្រនេះ។

### ៦.១ ការត្រួតពិនិត្យតាមដាន

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងតាមដានត្រួតពិនិត្យវឌ្ឍនភាពសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រប្រចាំឆ្នាំនីមួយៗធៀបនឹងលទ្ធផលរំពឹងទុក និងចំណុចដៅនៃសូចនាករកំណត់ និងធនធានដែលទទួលបានប្រចាំឆ្នាំ។ ការតាមដានត្រួតពិនិត្យត្រូវផ្អែកលើឧបករណ៍ដូចជាផែនការសកម្មភាពនិងរបាយការណ៍ប្រចាំឆ្នាំ។អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាដើម្បីកុមារត្រូវធ្វើរបាយការណ៍ពីលទ្ធផលនៃការតាមដានត្រួតពិនិត្យប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកែលម្អ និងផ្តល់អនុសាសន៍។

### ៦.២ ការវាយតម្លៃ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងវាយតម្លៃលទ្ធផលសម្រេចបានដោយផ្អែកលើសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ ការវាយតម្លៃនឹងធ្វើចំនួន០២ដង គឺការវាយតម្លៃពាក់កណ្តាលអាណត្តិនៅឆមាសទី២ឆ្នាំ២០២១និងការវាយតម្លៃបញ្ចប់អាណត្តិនៅឆមាសទី២ឆ្នាំ២០២៣។ ការវាយតម្លៃនេះនឹងផ្អែកលើឧបករណ៍ដូចជាផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍លទ្ធផល(សូចនាករលទ្ធផល)ប្រចាំឆ្នាំនីមួយៗរបាយការណ៍វាយតម្លៃវឌ្ឍនភាពពាក់កណ្តាលអាណត្តិ២០១៩-២០២១ និងរបាយការណ៍វាយតម្លៃវឌ្ឍនភាពបញ្ចប់អាណត្តិ២០១៩-២០២៣។

## ៧. សេចក្ដីសន្និដ្ឋាន

៧.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំកសាងឡើងនៅឆ្នាំ២០១៩ ក្រោមការដឹកនាំពីឯកឧត្តមប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងការចូលរួមរបស់សមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងផ្នែកជំនាញនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត ដោយមានការសម្របសម្រួលពិគ្រោះយោបល់ និងពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីដៃគូពាក់ព័ន្ធនានាដែលអនុវត្តសិទ្ធិកុមារ។

៧.២ ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន ក្រុមប្រឹក្សាជាតិដើម្បីកុមាររាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៥-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារនិងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ២០១៧-២០២១ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

៧.៣ ផែនការយុទ្ធសាស្ត្រនេះគឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កិច្ចការពារ និងពិនិត្យតាមដានការអនុវត្តសិទ្ធកុមារដែលគ្របដណ្ដប់លើគោលដៅយុទ្ធសាស្ត្រ៖១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស ៣.ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ ៤.ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួង-ស្ថាប័ន និង៥.បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្តរួមទាំងលទ្ធផលរំពឹងទុក និងសកម្មភាពជាយុទ្ធសាស្ត្រ។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យមានការចូលរួមគាំទ្រពីរាជរដ្ឋាភិបាល និងការគាំទ្រពីដៃគូពាក់ព័ន្ធ ព្រមទាំងសប្បុរសជននានា។ ផែនការយុទ្ធសាស្ត្រនេះនឹងធ្វើឱ្យមានភាពសុខដុមនីយកម្មរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរបស់ក្រសួង-ស្ថានប័ន និងផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត។ ផែនការយុទ្ធសាស្ត្រនេះនឹងឆ្លើយតបទៅនឹងសំណូមពររបស់ភាគីពាក់ព័ន្ធ និងជួយដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយដើម្បីធ្វើឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងករណីមានធនធានគាំទ្រគ្រប់គ្រាន់។

## ឧបសម្ព័ន្ធ៖

១-ជម្រើសនៃការពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងមន្ត្រីពាក់ព័ន្ធ

២-ម៉ាទ្រីចស្តីពីការត្រួតពិនិត្យតាមដាននិងវាយតម្លៃ

៣-ម៉ាទ្រីចស្តីពីតម្រូវការចំណាយ

ឧបសម្ព័ន្ធទី១

# ជម្រើសនៃការពង្រឹងសមត្ថភាព
# មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក និងមន្ត្រីពាក់ព័ន្ធ

ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីមានសារៈសំខាន់ដូចគ្នាសម្រាប់វិស័យសាធារណៈ និងវិស័យឯកជនដើម្បីធានាបាននូវប្រសិទ្ធភាពការងារ។ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងសហការជាមួយអ្នកពាក់ព័ន្ធដើម្បីបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអ្នកពាក់ព័ន្ធឱ្យមានសមត្ថភាពដើម្បីបំពេញមុខងាររបស់ខ្លួន។ ជំហានសម្រាប់ដំណើរការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពគឺត្រូវអនុវត្តដូចខាងក្រោម៖

- កំណត់តម្រូវការបណ្តុះបណ្តាល និងការអភិវឌ្ឍ
- បង្កើតគោលដៅ និងសូចនាករជាក់លាក់
- ជ្រើសរើសវិធីសាស្ត្របណ្តុះបណ្តាល និងការអភិវឌ្ឍ
- រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍ
- វាយតម្លៃលទ្ធផលការបណ្តុះបណ្តាល និងការអភិវឌ្ឍ

វិធីសាស្ត្រសម្រាប់បណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីមានជម្រើសគឺ ការហ្វឹកហាត់លើការងារផ្ទាល់ដោយមានការណែនាំ បើកវគ្គបណ្តុះបណ្តាលខ្លីៗ បញ្ជូនមន្ត្រីឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធ បញ្ជូនមន្ត្រីឱ្យទៅចូលរួមសិក្ខាសាលាទាំងនៅក្នុងប្រទេសនិងនៅក្រៅប្រទេស ព្រមទាំងបញ្ជូនមន្ត្រីឱ្យទៅរៀនជំនាញវិជ្ជាជីវៈនៅតាមគ្រឹះស្ថានឧត្តមសិក្សានានា។

ជម្រើសសម្រាប់បណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពមន្ត្រី ក.ជ.ក និងមន្ត្រីពាក់ព័ន្ធ

| ការប្រៀបធៀប | ការបណ្តុះបណ្តាល | ការអភិវឌ្ឍន៍សមត្ថភាព |
|---|---|---|
| អត្ថន័យ | ការបណ្តុះបណ្តាលគឺជាដំណើរការសិក្សាមួយដែលមន្ត្រីទទួលបានឱកាសដើម្បីអភិវឌ្ឍជំនាញ និងចំណេះដឹងវិជ្ជាជីវៈតាមតម្រូវការការងារ។ | ការអភិវឌ្ឍន៍សមត្ថភាពគឺជាដំណើរការអប់រំដែលពាក់ព័ន្ធនឹងការរីកចម្រើនរបស់មន្ត្រី។ |
| រយៈពេល | រយៈពេលខ្លី | រយៈពេលវែង |
| ផ្តោតលើ | បច្ចុប្បន្ន | អនាគត |
| ការតម្រង់ទិស | តម្រង់ទិសការងារ | តម្រង់ទិសភារកិច្ច |
| ការលើកទឹកចិត្ត | គ្រូបង្គោល | ផ្ទាល់ខ្លួន |
| ទិសដៅ | ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រី | ដើម្បីរៀបចំមន្ត្រីទទួលខុសត្រូវនាពេលអនាគត |
| ចំនួនមន្ត្រី | ច្រើននាក់ | ម្នាក់ៗ |
| គោលបំណង | ពាក់ព័ន្ធផ្ទាល់នឹងការងារ | ចំណេះដឹងទូទៅ |

ឧបសម្ព័ន្ធទី២៖ ម៉ាទ្រីចស្តីពីការត្រួតពិនិត្យតាមដាននិងវាយតម្លៃ

| ល.រ | សូចនាករ | ឯកតា | ទិន្នន័យ (2018) | ចំណុចដៅតាមឆ្នាំ | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | 2019 | 2020 | 2021 | 2022 | 2023 | | |
| 1 | **ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ** | | | | | | | | | |
| 1.1 | ចំនួនលិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងសិទ្ធិកុមារត្រូវបានរៀបចំនិងបង្កើតឡើង | ច្បាប់ | | 2 | 2 | 3 | 3 | 3 | រដ្ឋបាល | ផ្នែកការពារ |
| 1.2 | ចំនួនការអនុវត្តសិទ្ធកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានចុះពិនិត្យតាមដាន | ដង | | 6 | 24 | 24 | 24 | 24 | រដ្ឋបាល | ផ្នែកការពារ |
| 1.3 | ចំនួនកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិត្រូវបានរៀបចំឡើង | លើក | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែកការពារ |
| 1.4 | ចំនួនកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធ និងប្រមូលទិន្នន័យស្តីពីស្ថានភាពកុមារជាមួយអ្នកពាក់ព័ន្ធត្រូវបានរៀបចំឡើង | លើក | | 1 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែកការពារ |
| 1.5 | ឧបករណ៍ M&E tools សម្រាប់ប្រមូលព័ត៌មាន ឬទិន្នន័យអនុវត្តសិទ្ធិកុមារត្រូវបានបង្កើតឡើង | ឧបករណ៍ | | រៀបចំ | បង្កើត (1) | អនុវត្ត | អនុវត្ត | អនុវត្ត | រដ្ឋបាល | ផ្នែកការពារ |
| 1.6 | ចំនួនមន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ M&E tools សម្រាប់ប្រមូលព័ត៌មាន/ទិន្នន័យ | នាក់ | | 0 | 20 | 50 | 50 | 50 | រដ្ឋបាល | ផ្នែកការពារ |
| 1.7 | របាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារត្រូវបានចងក្រងឡើង | របាយការណ៍ | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែកការពារ |
| 1.8 | ចំនួនសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារត្រូវបានរៀបចំឡើង | លើក | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ផ្នែកការពារ |
| 1.9 | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាពិនិត្យនិងកំណត់សូចនាករពាក់ព័ន្ធសិទ្ធិកុមារត្រូវបានរៀបចំឡើង | លើក | | 2 | 6 | 6 | 6 | 6 | រដ្ឋបាល | ផ្នែកការពារ |
| 2 | **បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍធនធានមនុស្ស** | | | | | | | | រដ្ឋបាល | |
| 2.1 | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាផ្សព្វផ្សាយស្តីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិ | លើក | | 2 | 6 | 7 | 10 | 10 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | កុមារត្រូវបានរៀបចំឡើង | | | | | | | | | |
| 2.2 | ចំនួនសៀវភៅរូបភាពពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង | ក្បាល | | 1000 | 1500 | 1500 | 2000 | 2500 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.3 | ចំនួនផ្ទាំងរូបភាពពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង | សន្លឹក | | 925 | 1000 | 1125 | 1125 | 1000 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.4 | ចំនួនស្លតពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង | ស្លត | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.5 | ចំនួនបណ្ណផ្ទត់ពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង | សន្លឹក | | 5000 | 5000 | 5000 | 5000 | 5000 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.6 | ចំនួនព្រឹត្តិបត្រព័ត៌មានពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានផលិតឡើង | ក្បាល | | 500 | 500 | 500 | 500 | 500 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.7 | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាពិនិត្យឡើងវិញពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង | លើក | | 2 | 3 | 4 | 5 | 5 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.8 | ចំនួនកិច្ចប្រជុំរៀបចំមេរៀនស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង | លើក | | 1 | 2 | 2 | 1 | 2 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.9 | ចំនួនមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក ទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ | នាក់ | | 10 | 15 | 20 | 20 | 20 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.10 | ចំនួនក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័នទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ | នាក់ | | 10 | 20 | 25 | 20 | 30 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.11 | ចំនួនមន្ត្រីលេខាធិកាដ្ឋាន ក.ជ.ក រាជធានីខេត្តទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ | នាក់ | | 10 | 20 | 30 | 20 | 25 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 2.12 | ចំនួនបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលសិទ្ធិកុមារ | នាក់ | | 30 | 30 | 40 | 40 | 40 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |
| 1.13 | ចំនួនអ្នកដែលបានចូលរួមទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភព | នាក់ | | 3200 | 3200 | 3200 | 3200 | 3200 | រដ្ឋបាល | ផ្នែកផ្សព្វផ្សាយ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | លោកប្រឆាំងពលកម្មកុមារនៅថ្នាក់ជាតិ | | | | | | | | | |
| 3 | **ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ** | | | | | | | | | |
| 3.1 | ចំនួនមន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលជំនាញផ្នែករដ្ឋបាល រៀបចំផែនការ និងជំនាញពាក់ព័ន្ធ | នាក់ | | 10 | 25 | 30 | 40 | 30 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.2 | ចំនួនមន្ត្រីពាក់ព័ន្ធទទួលបានការអភិវឌ្ឍសមត្ថភាពនៅតាមគ្រឹះស្ថានអប់រំដើម្បីបង្កើនសមត្ថភាព | នាក់ | | 2 | 4 | 5 | 7 | 8 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.3 | ចំនួនផែនការថវិកាកម្មវិធី និងផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានចងក្រងរៀបចំឡើង | ផែនការ | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.4 | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាដើម្បីកៀរគរទាំងថវិកា និងបច្ចេកទេសត្រូវបានរៀបចំឡើង | លើក | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.5 | ចំនួនកិច្ចប្រជុំ ក.ជ.ក ត្រូវបានរៀបចំឡើង | លើក | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.6 | ចំនួនទស្សនៈកិច្ចសិក្សាពាក់ព័ន្ធកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារត្រូវបានរៀបចំឡើង | លើក | | 1 | 2 | 4 | 5 | 3 | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 3.7 | អង្គភាពថវិកាសម្រាប់អគ្គលេខាធិការដ្ឋាន ក.ជ.កត្រូវបានបង្កើតនិងពង្រឹងសមត្ថភាព | អង្គភាព | | បង្កើត (1) | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | រដ្ឋបាល | ផ្នែករដ្ឋបាល ផែនការហិរញ្ញវត្ថុ |
| 4 | **ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន** | | | | | | | | រដ្ឋបាល | |
| 4.1 | ចំនួនក្រុមការងារដើម្បីកុមារក្រសួងស្ថាប័នត្រូវបានបង្កើតឡើង និងពង្រឹងពង្រីកសមត្ថភាព( ក្រុម )សម្រាប់១ក្រសួង-ស្ថាប័ន | ក្រុម | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារ ដើម្បីកុមារ |
| 4.2 | ចំនួនកិច្ចអន្តរាគមន៍ និងឆ្លើយតបចំពោះអំពើរំលោភសិទ្ធិកុមារ ត្រូវបានអនុវត្ត( ដង )សម្រាប់១ក្រសួង-ស្ថាប័ន | លើក | | 2 | 6 | 6 | 6 | 6 | រដ្ឋបាល | ក្រុមការងារ ដើម្បីកុមារ |
| 4.3 | ចំនួនសមាជិកក្រុមការងារដើម្បីកុមាររបស់ក្រសួងស្ថាប័នត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងតួនាទីក្រុមការងារដើម្បីកុមារ( នាក់ ) | នាក់ | | 10 | 25 | 25 | 25 | 25 | រដ្ឋបាល | ក្រុមការងារ ដើម្បីកុមារ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សម្រាប់១ក្រសួង-ស្ថាប័ន | | | | | | | | | |
| 4.4 | ចំនួនកិច្ចប្រជុំដើម្បីពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង-ស្ថាប័ន | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារដើម្បីកុមារ |
| 4.5 | ចំនួនកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង-ស្ថាប័ន | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារដើម្បីកុមារ |
| 4.6 | ចំនួនកិច្ចប្រជុំបញ្ជ្រាបបញ្ហាកុមារនិងលើកកម្ពស់សិទ្ធិកុមារទៅក្នុងផែនការ កម្មវិធីរបស់ក្រសួង-ស្ថាប័នត្រូវបានរៀបចំឡើង(លើក) សម្រាប់១ក្រសួង-ស្ថាប័ន | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារដើម្បីកុមារ |
| 4.7 | ចំនួនកិច្ចប្រជុំសម្របសម្រួលរវាងអង្គការពាក់ព័ន្ធជាមួយក្រសួងត្រូវបានរៀបចំឡើង(លើក)សម្រាប់១ក្រសួង-ស្ថាប័ន | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារដើម្បីកុមារ |
| 4.8 | ចំនួនទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារត្រូវបានរៀបចំឡើង(នាក់)សម្រាប់១ក្រសួង-ស្ថាប័ន | ទិវា | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | ក្រុមការងារដើម្បីកុមារ |
| **5** | **បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្ត** | | | | | | | | រដ្ឋបាល | |
| 5.1 | ចំនួនក.ជ.ក រាជធានីខេត្ត លេខាធិការដ្ឋានត្រូវបានកែសម្រួលសមាសភាព និងពង្រឹងសមត្ថភាព(ខេត្ត)សម្រាប់១រាជធានី-ខេត្ត | អង្គភាព | | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.2 | ចំនួនកិច្ចអន្តរាគមន៍ និងឆ្លើយតបចំពោះអំពើរំលោភសិទ្ធិកុមារ ត្រូវបានអនុវត្ត(ដង)សម្រាប់១រាជធានី-ខេត្ត | លើក | | 10 | 24 | 24 | 24 | 24 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.3 | ចំនួនសមាជិក ក.ជ.ក រាជធានីខេត្តត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងតួនាទី ក.ជ.ក (នាក់)សម្រាប់១រាជធានី-ខេត្ត | នាក់ | | 13 | 26 | 26 | 26 | 26 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.4 | ចំនួនមន្ត្រីពាក់ព័ន្ធរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ (នាក់) សម្រាប់១រាជធានី-ខេត្ត | នាក់ | | 20 | 50 | 50 | 50 | 50 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.5 | ចំនួនកិច្ចប្រជុំពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅក្នុងរាជធានីខេត្ត | ប្រជុំ | | 1 | 2 | 2 | 2 | 2 | រដ្ឋបាល | លេខាធិការដ្ឋាន |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | | | | | | | | | ក.ជ.ក |
| 5.6 | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការលើកសិទ្ធិកុមារត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.7 | ចំនួនកិច្ចប្រជុំបញ្ជ្រាបបញ្ហាកុមារនិងលើកកម្ពស់សិទ្ធិកុមារទៅក្នុងផែនការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.8 | ចំនួនកិច្ចប្រជុំស្តីពីការលើកកម្ពស់សិទ្ធិកុមារជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូពាក់ព័ន្ធនៅក្នុងរាជធានីខេត្តត្រូវបានរៀបចំឡើង(លើក)សម្រាប់១រាជធានី-ខេត្ត | ប្រជុំ | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.9 | ចំនួនទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារត្រូវបានរៀបចំឡើង(ទិវា)សម្រាប់១រាជធានី-ខេត្ត | ទិវា | | 1 | 1 | 1 | 1 | 1 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |
| 5.10 | របាយការណ៍វឌ្ឍនភាពសូចនាករពាក់ព័ន្ធសិទ្ធិកុមារប្រចាំឆមាស និងប្រចាំឆ្នាំត្រូវបានចងក្រងឡើង(របាយការណ៍) | របាយការណ៍ | | 0 | 2 | 2 | 2 | 2 | រដ្ឋបាល | លេខាធិការដ្ឋាន ក.ជ.ក |

## ឧបសម្ព័ន្ធទី៣៖ ម៉ាទ្រីចស្តីពីតម្រូវការចំណាយ

| ពិពណ៌នា( គោលដៅយុទ្ធសាស្ត្រ) | | តម្រូវការថវិកាUSD | | រយៈពេលអនុវត្ត | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ថវិការដ្ឋ | ថវិកាដៃគូ | 2019 | 2020 | 2021 | 2022 | 2023 | |
| 1 | ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ | 306,200 | 30% | 4,1900 | 85,200 | 57,200 | 58,700 | 63,200 | **306,200** |
| 2 | បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស | 457,000 | 40% | 75,050 | 86,200 | 95,950 | 98,350 | 101,450 | **457,000** |
| 3 | ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ | 77,951 | 10% | 12,351 | 17,700 | 16,900 | 15,600 | 15,400 | **77,951** |
| 4 | ពង្រឹងនិងពង្រីកក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន[13] | 68,500 | 20% | 11,100 | 14,350 | 14,350 | 14,350 | 14,350 | **68,500** |
| 5 | បង្កើនការអប់រំផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ រាជធា-នីខេត្ត[14] | 68,900 | 30% | 11,850 | 14,650 | 14,600 | 14,400 | 14,400 | **69,900** |
| សរុបថវិកាសម្រាប់រយៈពេល៥ឆ្នាំ | | **979,551** | | **152,251** | **218,100** | **199,000** | **201,400** | **208,800** | **979,551** |

[13]តម្រូវការចំណាយសម្រាប់ ១ក្រសួង-ស្ថាប័ន ( សម្រាប់ក្រសួង-ស្ថាប័មានក្រុមការងារដើម្បីកុមារ )

[14]តម្រូវការចំណាយសម្រាប់ ១រាជធានី-ខេត្ត ( សម្រាប់រាជធានី-ខេត្តដែលបានបង្កើត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី-ខេត្ត និងលេខាធិការដ្ឋាន )